# របាយការណ៍ប្រចាំខែកញ្ញា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែកញ្ញា ឆ្នាំ ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **ស្ថានភាពមន្ត្រីរាជការ**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣១ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **សកម្មភាពថ្នាក់ដឹកនាំមន្ទីរ**÷

- ចូលរួមវេទិកាសាធារណៈ ចំនួន ០៥ លើក
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៥ អាណត្តិទី២ ឆ្នាំទី២ របស់ក្រុមប្រឹក្សាខេត្ត នៅថ្ងៃទី ២០/០៨/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមពិនិត្យ និងសិក្សាពីស្ថានភាពប្រើប្រាស់ដីក្នុងបរិវេណដីសម្បទានសង្គមកិច្ច ឃុំថ្មគ្រែ ថ្ងៃទី ២១/០៨/២០១៥ នៅឃុំថ្មគ្រែ
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគារសិក្សាវិទ្យាល័យថ្មគ្រែ ថ្ងៃទី ២១/០៨/២០១៥ នៅឃុំថ្មគ្រែ
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធីសម្ពោធអគារសិក្សាថ្មរាបថ្ងៃទី២២/០៨/២០១៥ នៅភូមិថ្មរាប
- ចូលរួមសិក្សាផ្សព្វផ្សាយ ស្ដីពីការផ្ដើមអនុវត្តកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ថ្ងៃទី ០១/០៩/២០១៥ នៅសណ្ឋាគារ លីជី
- ចូលរួមពិនិត្យ វាយតម្លៃ ប្រគល់ ទទួលការផ្គត់ផ្គង់សម្ភារៈការិយាល័យជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រចេះ ថ្ងៃទី០២/០៩/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សាថ្នាក់ក្រោមជាតិលើសេចក្ដីព្រាងយុទ្ធសាស្ត្រវេជប្លូកកម្ពុជា ថ្ងៃទី០៨-០៩/០៩/២០១៥ នៅសណ្ឋាគារលីជី
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យប្រចាំសី ២០១៥ ថ្ងៃទី១០/០៩/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមបើកសិក្ខាសាលា ស្ដីពីសេចក្ដីសន្និដ្ឋាន ៥២ ចំណុចលើរបាយការណ៍ជាតិលើកទី៤ និងទី៥ អនុសញ្ញាលុបបំបាត់ការរើសអើងប្រឆាំងនឹងនារី ថ្ងៃទី១៤/០៩/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមសិក្ខាសាលាស្ដីពី ការវាយតម្លៃលទ្ធផលសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជា ២០១៣-២០១៥ ថ្ងៃទី១៨/០៩/២០១៥ នៅសណ្ឋាគារ ៧ មករា ខេត្តកំពង់ចាម

- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីប្រារព្ធទិវាអក្ខរកម្មជាតិ០៨/០៩/២០១៥ និងថ្ងៃទី១៦/០៩/២០១៥ នៅឃុំស្វាយជ្រះ
- ចូលរួមប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការទប់ស្កាត់យានយន្តដឹកលើសទម្ងន់បើកបរលើផ្លូវជនបទ ថ្ងៃទី១៦/០៩/២០១៥ នៅរាជធានីភ្នំពេញ
- ចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍របស់អង្គការ CHOBA និងអង្គការ WASHOBA ថ្ងៃទី២២/០៩/២០១៥ នៅខេត្តកំពង់ចាម
- ចូលរួមសិក្ខាសាលាបញ្ចប់គម្រោងបញ្ញាបយេនឌ័រ ថ្ងៃទី០៨/០៩/២០១៥ នៅសណ្ឋាគារភ្នំពេញរាជធានីភ្នំពេញ។

3. **<u>សកម្មភាពតាមការិយាល័យ</u>**÷

3.1. **<u>ការិយាល័យរដ្ឋបាល និងបុគ្គលិក</u>**÷

ក. <u>ផ្នែកការងារលិខិតចូល</u>÷ សរុបចំនួន ៧២ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ៧ លេខ
- លិខិតរបស់ក្រសួងសាមី ចំនួន ១២ លេខ
- លិខិតក្រសួងនានា ចំនួន ១៤ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៣៩ លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ៣១ លេខ ក្នុងនោះមានៈ

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ០៧ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ២៤ លេខ

គ-<u>លិខិតឧទ្ទេសនាម</u>÷ សរុបចំនួន ០២លេខ

ឃ. <u>ផ្នែកការងារលិខិតបញ្ជាបេសកកម្ម</u>÷ សរុបចំនួន ២០ លេខ

- ផ្ញើសំណើសុំលិខិតបញ្ជាបេសកកម្មលោកប្រធានមន្ទីរ ពី **ឯកឧត្តមអភិបាលខេត្ត** ចំនួន ០២ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ១៨ លេខ

ង. <u>ផ្នែកបញ្ជីវត្តមាន</u>÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **<u>ការិយាល័យផ្លូវជនបទ</u>**÷

**<u>សកម្មភាពការងារ</u>**

- ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ចំនួន ៧ខ្សែ ប្រវែង ១៥៧ ៩០០ ម៉ែត្រ ស្ថិតនៅ ឃុំកញ្ជរ ឃុំដីវីផុង ឃុំកពង់ដីវី ស្រុកឆ្លូង និង ឃុំស្វាយជ្រះ ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ
- ចុះពិនិត្យការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប សំរ៉ង-ចឹង ប្រវែង ៨ ០០០ ម៉ែត្រ ស្ថិតនៅ ឃុំ ឃ្សឹម និងផ្លូវក្បាលស្នួល-ស្នួលកើត ប្រវែង ៤ ០០០ ម៉ែត្រ ស្ថិតនៅឃុំស្នួល ស្រុកស្នួល បានចំនួន ៣លើក

- ក្រុមការងារក្រសួង និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានចុះពិនិត្យនិងវាយតម្លៃការងារបញ្ចប់ជួសជុលបន្ទាន់ផ្លូវបុកទឹក-ព្រែកក្រាំង ប្រវែង ២ ៧០០ ម៉ែត្រ ស្ថិតនៅឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ
- ចុះពិនិត្យការងារជួសជុលផ្លូវ ពីភូមិខ្សាត់ទៅភូមិស្ទឹងទ្រ ប្រវែង ៦ ៨០០ ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ បានចំនួន ២ លើក
- ចុះបញ្ជាក់បច្ចេកទេសលើព័ត៌មានគម្រោងមូលនិធិឃុំ សង្កាត់ របស់ទីចាត់ការផែនការនិងវិនិយោគសាលាខេត្តក្រចេះ បានចំនួន ០៣ ច្បាប់។

**លទ្ធផលការងារ ÷**

- • ការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប សំរ៉ង-ចឹង ប្រវែង ៨ ០០០ ម៉ែត្រ ស្ថិតនៅឃុំឃ្សឹម និងផ្លូវ ក្បាលស្នួល-ស្នួលកើត ប្រវែង ៤ ០០០ ម៉ែត្រ ស្ថិតនៅឃុំស្នួល ស្រុកស្នួល លទ្ធផលសម្រេចបាន ១០០%
- ការងារជួសជុលផ្លូវភូមិខ្សាត់ទៅភូមិស្ទឹងទ្រ ប្រវែង ៦៨០០ ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ លទ្ធផលសម្រេចបាន ១០%
- ការងារជួសជុលថែទាំជាលក្ខណៈប្រចាំផ្លូវស្រែទ្រៀក-វាលកន្សែងប្រវែង ៦ ៣០០ ម៉ែត្រ ស្ថិតនៅឃុំជីវីធុង ស្រុកឆ្លូង និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង លទ្ធផលសម្រេចបាន ៨០%។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ**÷

- ចុះជួសជុលអណ្តូងស្នប់បានចំនួន ០៧ អណ្តូង ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ។

3.4. **ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**÷ (គ្មានសកម្មភាព)

3.5. **ការិយាល័យអភិវឌ្ឍន៍សហគមន៍**÷

- ចុះបណ្តុះបណ្តាល គ.អ.ភ នៅស្រុកឆ្លូង ស្តីពី÷ការដោះស្រាយទំនាស់តាមសហគមន៍ បានចំនួន ០៥ វគ្គ ស្មើនឹង ២០ ភូមិ ស្មើនឹង ០៤ ឃុំ និងមាន គ.អ.ភ ចូលរួមចំនួន ១៥៥ នាក់ ក្នុងនោះស្ត្រីមាន ៤១ នាក់។

3.6. **ការិយាល័យជនជាតិដើមភាគតិច**÷

- ចូលរួមសិក្ខាសាលាកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិស្តីពី សេចក្តីព្រៀងយុទ្ធសាស្ត្រ (រេដបូក) ជាតិលើកទី០៤ ខេត្តក្រចេះ សណ្ឋាគារ លី ធី។

3.7. **ការិយាល័យថែទាំសុខភាពជនបទ**÷

- ចែកសម្ភារៈសាងសង់បង្គន់អនាម័យ តាមគ្រួសារនៅឃុំជ្រោយបន្ទាយបានចំនួន ១០០ សម្រាប់
- ចុះត្រួតពិនិត្យការងារសាងសង់បង្គន់តាមគ្រួសារនៅជ្រោយបន្ទាយបានចំនួន ១០០ បង្គន់ ឃុំកញ្ជរ ២០ បង្គន់ និងឃុំព្រែកសាម៉ាន់ ១១ បង្គន់
- បំផុសអោយប្រជាពលរដ្ឋចូលរួមស្មគ្រ័ចិត្តសាងសង់បង្គន់ខ្លួនឯង នៅស្រុកព្រែកប្រសព្វ ៩៦ បង្គន់ និងស្រុកឆ្លូង ៣៧ បង្គន់ ។

3.8. <u>**ការងារបណ្តុះបណ្តាលមន្ត្រីរាជការ**</u>÷ មានចំនួន ៦លើក។